ព្រឹត្តិប័ត្រប្រចាំត្រីមាស

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

The NGO FORUM ON CAMBODIA

# ដី ជីវិត

ឆ្នាំទី៣ ~ លេខ០៩

ខែមករា ~ ខែមីនា ឆ្នាំ២០០៨

បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍

- សិទ្ធិជនជាតិដើមភាគតិចត្រូវបានរំលោភដោយសារការ...
- ការចុះបញ្ជីដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ការឈូសឆាយព្រៃធម្មជាតិ គឺជាទុក្ខកង្វល់របស់សហគមន៍
- ស្ថានភាពទំនាស់ដីធ្លី និងព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា...
- ទិដ្ឋភាពរួមនៃការវិភាគករណីវិវាទដីធ្លីក្នុងខេត្តបីនៃ...
- គំនូសតារាងបង្ហាញអំពីដំណាក់កាលចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ



## កម្មវិធីដីធ្លី និងជីវភាព

១- គំរោងបញ្ហាដីធ្លី

២- គំរោងការរុះរើតាំងទីលំនៅថ្មី និងសិទ្ធិលំនៅឋាន

៣- គំរោងសិទ្ធិជនជាតិដើមភាគតិច

៤- គំរោងជីវភាពអាស្រ័យព្រៃឈើ និងចំការឈើដាំ

ព្រឹត្តិប័ត្រប្រចាំត្រីមាស

ឆ្នាំទី៣ ~ លេខ០៩

ខែមករា ~ ខែមីនា ឆ្នាំ២០០៨

# ដីជីវិត

## បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍

### អារម្ភកថា

មិត្តអ្នកអានជាទីមេត្រី ព្រឹត្តិប័ត្រដែលកំពុងស្ថិតក្នុងដៃរបស់អស់លោកអ្នកនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងរបស់បុគ្គលិកនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាដោយមានការចូលរួមចំណែកពីសមាជិកបណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍ បណ្តាញប្រព្រឹត្តិកម្មតាំងទីលំនៅថ្មី បណ្តាញគាំទ្រសិទ្ធិជនជាតិដើមភាគតិច និងបណ្តាញការងារព្រៃឈើ និងចំការឈើដាំ។ ក្នុងនាមវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលមានជំហរលើការចែករំលែកព័ត៌មាន ជជែកពិភាក្សាលើការផ្លាស់ប្តូរគោលនយោបាយ និងសកម្មភាពអភិវឌ្ឍន៍នៅកម្ពុជា យើងសូមគាំទ្រដល់ការបោះពុម្ពព្រឹត្តិប័ត្រនេះដើម្បីចូលរួមចំណែកផ្តល់នូវចំណេះដឹងនានាដែលពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងដើម្បីអោយមិត្តអ្នកអានបានដឹងថា នរណាខ្លះដែលកំពុងនឹងបានក្លាយខ្លួនទៅជាក្រុមជនងាយរងគ្រោះដោយសារការបាត់បង់ដីធ្លីនៅកម្ពុជា។

លើសពីនេះទៀត ព្រឹត្តិប័ត្រនេះក៏បានលើកឡើងនូវសំលេង និងផលវិបាកទាំងអស់របស់ប្រជាពលរដ្ឋក្រីក្រទាក់ទងទៅនឹងបញ្ហាដីធ្លីដើម្បីអោយ អ្នកធ្វើគោលនយោបាយទាំងអស់បានដឹងឮ និងងាកមកយកចិត្តទុកដាក់នូវអ្វីដែលជាអាទិភាពសំរាប់ឆ្លើយតបទៅនឹងតំរូវការរបស់បងប្អូន។

យើងខ្ញុំសូមបើកចំហរដើម្បីទទួលនូវមតិយោបល់កែលំអ និងស្វាបនាអោយមានភាពជឿនលឿនទាំងផ្នែកព័ត៌មាន និងចំណេះដឹងយើងខ្ញុំនឹងព្យាយាមបំពេញតាមតំរូវការរបស់អស់លោកអ្នក។

ព្រឹត្តិប័ត្រប្រចាំត្រីមាស

គណៈកម្មការនិពន្ធ និងត្រួតពិនិត្យ

លោក ឈិត សំអាត

លោក ឌី សន

លោក ជាម មុនី

លោក ហិប សុខាន់ណារ៉ូ

លោក ម៉ិច សុខន

អាស័យដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ ទួលទំពូង១
ភ្នំពេញ, កម្ពុជា
ទូរស័ព្ទលេខ: ០២៣ ២១៤ ៤២៩
ទូរសារ: ០២៣ ៩៩៤ ០៦៣









# សិទ្ធិជនជាតិដើមភាគតិចត្រូវបានរំលោភ ដោយសារការផ្តល់សម្បទានដីសេដ្ឋកិច្ច

សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ របៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។ សមាជិកនៃសហគមន៍ជនជាតិដើមភាគតិច អាចទទួលនូវគុណប្រយោជន៍ពីការធានាសិទ្ធិ និងការការពារដែលរៀបចំឡើងដោយច្បាប់ (ច្បាប់ភូមិបាល) ចំពោះរាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិពន្ធុអំពីវប្បធម៌ និងសង្គមរបស់សហគមន៍។ ដីសហគមន៍ចង្កុំមួយ ចង្កុំកណ្តាល និងភូមិកោះ ថ្ម ស្ថិតនៅក្នុង ឃុំ ទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម កំពុងប្រឈមទៅនឹងបញ្ហាដែលដីដំណាំ និងដីបំរុងទុកសំរាប់ចំការវិលជុំរបស់ពួកគេទំហំ ៤២៧១ ហិចតា កំពុងត្រូវបានឈូសឆាយដោយក្រុមហ៊ុន ចំនួនបី គឺក្រុមហ៊ុន **ផល សុទ្ធី** មានផ្ទៃដីទំហំ ១000ហិចតា ក្រុមហ៊ុន **ស្រ៊ុន ផាន់ឡេង** មានផ្ទៃដីទំហំ ៨00 ហិចតា និងក្រុមហ៊ុន **ហេង ឆែនឹម** មានផ្ទៃដីទំហំ ៨00 ហិចតា ដែលក្រុមហ៊ុនទាំងនោះ ដាំដំឡូងមី និងដាំកូនកៅស៊ូ ហើយគ្រឿងចក្រដែលឈូសឆាយនោះត្រូវបានការពារដោយទាហានវរៈសេនាតូចលេខ ២១២ ដែលមានទីតាំងនៅក្នុងឃុំទន្លូង។ លើសពីនេះទៅទៀតទាហានដែលការពារគ្រឿងចក្រនោះ បានធ្វើការគំរាមកំហែងប្រជាពលរដ្ឋជនជាតិដើមទាំងនោះនៅពេល ដែលពួកគេបានទៅធ្វើការហាមឃាត់





រូបភាពគ្រឿងចក្រធ្វើការឈូសឆាយដោយមានទាហានការពារ និងរូបភាពសាកសួរប្រជាពលរដ្ឋពីផលប៉ះពាល់

ជនជាតិដើមភាគតិច ជាដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី ដីដែលបានដាំដុះជាក់ស្តែង និងដីបំរុងទុកចាំបាច់ក្នុងការប្តូរវេនដាំដំណាំ ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយគ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់ជនជាតិដើមភាគតិចបានឡើយ (មាត្រា ២៨នៃច្បាប់ភូមិបាល)។

បើទោះជាយ៉ាងនេះក្តី តាមស្ថានភាពបច្ចុប្បន្ន ដោយសារតែការកើនឡើងនៃតំលៃដី និងដើម្បីសម្របសម្រួលអោយត្រូវទៅនឹងគោលនយោបាយអភិវឌ្ឍន៍ក្រោមរូបភាពយន្តការនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច ដូចនេះសិទ្ធិជាមូលដ្ឋាន និងទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិដើមភាគតិចនៅកន្លែងមួយចំនួន មិនត្រូវបានគេយកមកពិចារណា និងផ្តល់នូវសិទ្ធិដែលពួកគេត្រូវទទួលបាននោះឡើយ។ ជាក់ស្តែងជនជាតិភាគតិច ស្ទៀង ចំនួន ១៤៥ គ្រួសារ ដែលរស់នៅក្នុងភូមិគ្រឿងចក្រដើម្បីបញ្ឈប់ការឈូសឆាយដីសហគមន៍របស់ពួកគេ។

តាមការសាកសួរប្រជាពលរដ្ឋនៅក្នុងសហគមន៍ព្រមទាំងលោកមេឃុំ និងក្រុមគ្រួសាររបស់លោក បានអះអាងថា ពួកគេពិតជាជនជាតិភាគតិចស្ទៀង ដែលបានរស់នៅក្នុងឃុំទន្លូង តាំងពីដូនតាមកម្លេះ ហើយរស់នៅតាមរបៀបទំនៀមទំលាប់ប្រពៃណីដោយដាំដំណាំ និងធ្វើចំការវិលជុំ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ប្រជាពលរដ្ឋបញ្ជាក់ថាការឈូសឆាយរបស់ក្រុមហ៊ុនធ្វើអោយបាត់បង់ដីរបស់សហគមន៍ជនជាតិដើមភាគតិច បាត់បង់ដីបំរុងទុកសំរាប់ចំការវិលជុំ ទីកន្លែងចិញ្ចឹមសត្វ និងមិនអាចចូលព្រៃ ដើម្បីទទួលបាននូវអនុផលព្រៃឈើទៀតឡើយ ដែលជាហេតុប៉ះពាល់យ៉ាងខ្លាំងដល់បញ្ហាជីវភាព និងការចិញ្ចឹមជីវិតរបស់ពួកគេ។

មន្ត្រីសុរិយោដីស្រុកបានបំភ្លឺថា គណៈកម្មការដោះស្រាយវិវាទដីធ្លីថ្នាក់ស្រុកមួយត្រូវបានបង្កើតឡើង ដែលដឹកនាំដោយលោក

អភិបាលស្រុក បន្ទាប់ពីមានបណ្ដឹងតវ៉ារបស់ប្រជាពលរដ្ឋមក ថ្នាក់ស្រុក-ខេត្ត និងរដ្ឋសភាជាតិ។ គណៈកម្មការនេះបានចុះទៅដល់កន្លែងវិវាទ ហើយបានណែនាំប្រជាពលរដ្ឋអំពីច្បាប់ភូមិបាល និងច្បាប់ស្ដីពីព្រៃឈើ។ លោកអះអាងថា ប្រជាពលរដ្ឋទាំងនោះមិនមែនជាជនជាតិភាគតិចស្មៀងនោះទេ ព្រោះលោកពុំឃើញមានអ្វីជាសំគាល់នោះឡើយ លើសពីនេះទៅទៀត ដីដែលមានវិវាទនោះគឺជាដីរដ្ឋ ហើយរដ្ឋបានផ្ដល់ជាសម្បទានសេដ្ឋកិច្ចឱ្យទៅក្រុមហ៊ុនរួចហើយ ដើម្បីធ្វើការវិនិយោគក្នុងគោលបំណងការពារដីរដ្ឋជៀសវាងការទន្ទ្រានដោយខុសច្បាប់ពីអ្នកភូមិ។

តាមការអះអាងរបស់មន្ត្រីសុរិយោដីស្រុក គឺដើម្បីជៀសឱ្យផុតពីបទបញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងច្បាប់ភូមិបាល មាត្រា ២៣ ដល់មាត្រា ២៨ ក្នុងគោលបំណងដើម្បីកុំឱ្យប្រជាពលរដ្ឋអាចទាមទារថាជាដីសហគមន៍ជនជាតិដើមភាគតិច បើទោះបីជាប្រជាពលរដ្ឋខ្លួនឯង និងលោកមេឃុំបញ្ជាក់ថា ពួកគេជាជនជាតិភាគតិចក៏ដោយ។

*អត្ថបទដោយ លោក **ខៀវ ចាន់** មន្ត្រីស៊ើបអង្កេតនៃ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

## ការចុះបញ្ជីដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ជំហានសំខាន់ៗនៃការចុះបញ្ជីដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានដូចខាងក្រោម ៖

១-ការប្រកាសតំបន់វិនិច្ឆ័យ

២-បិទផ្សាយសាធារណៈ

៣-វាស់វែងកំណត់ព្រំ

៤-ដំណើរចុះបញ្ជី ... ឯកសារវិនិច្ឆ័យ

៥- ការផ្ដល់ប័ណ្ណ

គណៈកម្មការរដ្ឋបាល ត្រូវបានបង្កើតឡើងតែក្នុងដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។

ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ អនុវត្តជា ៥ ដំណាក់កាល ៖

### ដំណាក់កាលទី ១. ការរៀបចំ

អភិបាលខេត្ត/ក្រុង បន្ទាប់ពីបានពិភាក្សាឯកភាពជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់រួចមកត្រូវចេញសេចក្ដីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ តាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ។

បន្ទាប់ពីបានកំណត់តំបន់ធ្វើការវិនិច្ឆ័យរួចហើយ អភិបាលខេត្ត ក្រុងត្រូវចាត់តាំងគណៈកម្មការរដ្ឋបាល ដែលមានសមាសភាព៖

- តំណាងអភិបាលខេត្ត/ក្រុង ជាប្រធាន
- មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី ជាសមាជិក
- មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាល សុរិយោដីនៃមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត/ក្រុង ជាសមាជិក
- អភិបាលស្រុក-ខ័ណ្ឌ ឬតំណាង ជាសមាជិក
- មេឃុំ-ចៅសង្កាត់ ឬតំណាង ជាសមាជិក
- មេភូមិ ឬតំណាង ជាសមាជិក
- ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ២រូប ជាសមាជិក

អភិបាលខេត្ត/ក្រុង ត្រូវជូនដំណឹងជាសាធារណៈអំពីកាលបរិច្ឆេទ និងទីកន្លែងប្រជុំផ្សព្វផ្សាយសេចក្ដីប្រកាស កំណត់តំបន់ធ្វើការវិនិច្ឆ័យ។

**ការវិនិច្ឆ័យ** គឺជាដំណើរការមួយ ដែលកំណត់សិទ្ធិជាធរមានលើក្បាលដីជាស្ថាពរ និងមានលក្ខណៈជាផ្លូវការ។ ដំណើរការវិនិច្ឆ័យមិនធ្វើការកែប្រែសិទ្ធិជាធរមានលើក្បាលដី ឬបង្កើតសិទ្ធិថ្មីឡើយ។ បន្ថែមពីលើការកំណត់សិទ្ធិជាធរមាន ដំណើរការវិនិច្ឆ័យក៏កំណត់ផងដែរនូវបុគ្គលដែលជាម្ចាស់សិទ្ធិទាំងនោះ ព្រមទាំងលក្ខខណ្ឌនានា ដែលមានចំពោះសិទ្ធិទាំងនោះ (ដូចជាប្រភេទទ្រព្យ ៖ ទ្រព្យរួមប្ដី-ប្រពន្ធ, ទ្រព្យផ្ទាល់ខ្លួនខាងប្ដី, ទ្រព្យផ្ទាល់ខ្លួនខាងប្រពន្ធ, សហកម្មសិទ្ធិ, ទ្រព្យក្រុមហ៊ុន, ទ្រព្យសហគមន៍ ឬសមាគមន៍...)។ លទ្ធផលនៃការវិនិច្ឆ័យគឺការទទួលបាននូវបញ្ជីដីធ្លីមួយ ដែលមានលក្ខណៈពេញលេញច្បាស់លាស់ និងស្ថាពរ។

ដូច្នេះ ដើម្បីឱ្យលទ្ធផលនៃការវិនិច្ឆ័យសំរេចជោគជ័យស្របតាមគោលបំណងនៃការវិនិច្ឆ័យមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាល ត្រូវយកចិត្តទុកដាក់បំផុសឱ្យប្រជាពលរដ្ឋ ម្ចាស់ក្បាលដីត្រូវចុះបញ្ជី និងជនពាក់ព័ន្ធចូលរួម និងសហការផ្ដល់ព័ត៌មាន លើកសំណួរ យោបល់ ឬផ្ដល់ការជំទាស់ផ្សេងៗ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានភារកិច្ចត្រួតពិនិត្យលើភាពត្រឹមត្រូវលើការងារបច្ចេកទេស និងច្បាប់ក្នុងការកំណត់ព្រំដីការវាស់វែង និងការបំពេញទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងសំរបសំរួលការងារជាមួយអាជ្ញាធរមូលដ្ឋាន។

### ដំណាក់កាលទី ២ : ប្រតិបត្តិការបច្ចេកទេស

នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ ហើយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ មន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ដែលត្រូវបំពេញភារកិច្ចក្នុងតំបន់ធ្វើការវិនិច្ឆ័យ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ដែលបានទទួលសេចក្តីណែនាំពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រត្រូវទទួលខុសត្រូវចំពោះការវិនិច្ឆ័យ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិដឹកនាំចេញសេចក្តីណែនាំចាំបាច់ដល់មន្ត្រីជំនាញដែលបានតែងតាំង។

មន្ត្រីកំណត់ព្រំដី និងមន្ត្រីវាស់វែង មានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ដើម្បីកំណត់ព្រំដី និងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុ តាងផ្សេងៗ ទាក់ទងនឹងព្រំនៃក្បាលដីណាមួយ។

មន្ត្រីវិនិច្ឆ័យ មានសិទ្ធិសាកសួរយកព័ត៌មានចាំបាច់សំរាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនដែលពាក់ព័ន្ធអោយផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗទាក់ទងនឹងការវិនិច្ឆ័យ។

### ដំណាក់កាលទី៣ : ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមានប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ត្រូវមានរយៈវេលា ៣០ ថ្ងៃ នៅកន្លែងដែលងាយមើលឃើញ សំរាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ។

អាជ្ញាធរខេត្ត/ក្រុង ត្រូវផ្សព្វផ្សាយដំណឹងអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យតាមសំណើររបស់គណៈកម្មការរដ្ឋបាល។

ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ ជនដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកដែលមានផលប្រយោជន៍លើក្បាលដីណាមួយដែលបាន ចាត់ទុកថាឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ ឬមិនពេញលេញអាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន។

ក្រោយពីផ្តល់នូវការកត់សំគាល់ ដ៏សមហេតុផលដល់ជនគ្រប់រូបដែលពាក់ព័ន្ធនឹងការជំទាស់ និងបន្ទាប់ពីពិគ្រោះជាអ្នកដែលធ្វើការជំទាស់គណៈកម្មការរដ្ឋបាលត្រូវព្យាយាមដោះស្រាយតាមការព្រមព្រៀង។

ការជំទាស់ ឬវិវាទណាមួយដែលមិនអាចដោះស្រាយបានត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិស្របតាមនីតិវិធី ដែលបានកំណត់ដោយអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

ករណីមិនមានការជំទាស់ ឬតវ៉ាក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈ ទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹត ដែលអាចកំណត់យកជាផ្លូវការតាមច្បាប់បានលើកលែងចំពោះតែករណី ដែលសាមីអ្នកកាន់កាប់ដី ឬអចលនវត្ថុមានឯកសារសំអាងច្បាស់លាស់ ហើយបានបង្ហាញអំពីមូលហេតុដែលមិនបានមកធ្វើការជំទាស់ ឬតវ៉ាក្នុងរយៈពេលបិទផ្សាយនោះ សាមីជន អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការសុរិយោដី ដើម្បីដោះស្រាយតាមនីតិវិធីដែលបានកំណត់។

### ដំណាក់កាលទី ៤ : ការសំរេចលើឯកសារ

ក្រោយពីផុតរយៈពេល នៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ :

- មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី
- ប្រធានគណៈកម្មការរដ្ឋបាល ត្រូវចុះហត្ថលេខាលើប្លង់សុរិយោដីបញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ។
- ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត/ក្រុង ត្រូវចុះហត្ថលេខាបំពេញលើប្លង់សុរិយោដីបញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យត្រង់ចំណុចហត្ថលេខា អភិបាលខេត្ត/ក្រុង។
- អភិបាលខេត្ត/ក្រុង ត្រូវចុះហត្ថលេខាលើប្លង់សុរិយោដីបញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ។ ករណីមិនឯកភាព ត្រូវបញ្ជាក់ពីមូលហេតុអោយបានច្បាស់លាស់។
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ចុះហត្ថលេខាសំរេចជាផ្លូវការលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ។

នៅពេលដែលឯកសារនៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរឯកសារនៃការវិនិច្ឆ័យព្រមទាំងឯកសារទាំងអស់ ដែលទទួលបានក្នុងអំឡុងពេលនៃការវិនិច្ឆ័យត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដីដើម្បីចុះបញ្ជី។

### ដំណាក់កាលទី ៥ ការចេញប័ណ្ណ

ក្រោយពេលក្បាលដី ដែលមានក្នុងឯកសារនៃការវិនិច្ឆ័យ ត្រូវបានចុះបញ្ជី ហើយក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ (ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត/ក្រុង ដែល បានទទួលប្រតិភូកម្មពីក្រសួង) ត្រូវចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់ អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលើគ្រប់ក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យនេះ។

### ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មការរដ្ឋបាលក្នុងដំណើរការចុះបញ្ជីដីធ្លី

<u>សំគាល់</u> : កុំច្រឡំរវាងគណៈកម្មការរដ្ឋបាល (ចែងក្នុងមាត្រា ២៣៧ នៃច្បាប់ភូមិបាល) និងគណៈកម្មការសុរិយោដី (ចែងក្នុងមាត្រា ៤៧ នៃច្បាប់ភូមិបាល) និងរដ្ឋបាលសុរិយោដី (ចែងក្នុងមាតិកាទី ៦ នៃច្បាប់ភូមិបាល)។

ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលកំណត់ក្នុងអនុក្រឹត្យមាន :

- បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី
- ទទួលរាល់បណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង
- ធ្វើសេចក្តីសន្និដ្ឋាន ផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ
- លើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ។

ប៉ុន្តែជាក់ស្តែង គណៈកម្មការរដ្ឋបាល មានភារកិច្ចលំអិតនៅគ្រប់ដំណាក់កាលអនុវត្តន៍នីតិវិធីនៃការចុះបញ្ជីដី មានលក្ខណៈជាប្រព័ន្ធនេះជាអាទិ៍ :

#### នៅដំណាក់កាលទី ១ :

- បន្ទាប់ពីបង្កើតគណៈកម្មការរដ្ឋបាល ប្រធានគណៈកម្មការត្រូវរៀបចំប្រជុំណែនាំសមាជិករបស់ខ្លួនអោយយល់អំពីកិច្ចដំណើរការនៃការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធកំណត់បែងចែកភារកិច្ចដល់សមាជិកម្នាក់ៗ រៀបចំផែនការសំរាប់អនុវត្ត និងលើកសំណើទៅអភិបាលខេត្ត/ក្រុង អំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ និងការចុះបំពេញការងារទីវាលរបស់មន្ត្រីជំនាញ។
- ក្នុងឱកាសប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាល ត្រូវពន្យល់អំពីដំណើរការនៃការវិនិច្ឆ័យភាពចាំបាច់ និងឱកាសដែលត្រូវចូលរួមរបស់ប្រជាពលរដ្ឋជាម្ចាស់សិទ្ធិបំភ្លឺអំពីសិទ្ធិស្របច្បាប់លើអចលនវត្ថុ និងកាតព្វកិច្ចដែលត្រូវបំពេញ ព្រមទាំងឆ្លើយនូវរាល់សំនួរ ឬចម្ងល់ដែលបានលើកឡើងក្នុងអង្គប្រជុំ។ ផ្អែកលើសារៈសំខាន់ដូចបានបញ្ជាក់ខាងលើសេចក្តីជូនដំណឹង ត្រូវតែផ្សព្វផ្សាយអោយបានទូលំទូលាយ និងមានប្រសិទ្ធិភាព។កិច្ចប្រជុំបន្ថែមសំរាប់ថ្នាក់ភូមិ នឹងត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬអាជ្ញាធរមូលដ្ឋានចាត់ទុកជាការចាំបាច់។

#### នៅដំណាក់កាលទី ២ : គឺជាការងារជំនាញបច្ចេកទេសដែល មានការងារទីវាល និងការងារនៅការិយាល័យ។

#### នៅដំណាក់កាលទី ៣ :

- នៅពេលដែលឯកសារនៃការវិនិច្ឆ័យ ត្រូវបានរៀបចំរួចរាល់ហើយ គណៈកម្មការរដ្ឋបាលត្រូវលើកសំណើទៅអភិបាលខេត្ត/ក្រុង ដើម្បីធ្វើការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ដែលក្នុងនោះបញ្ជាក់អំពីទីកន្លែង និងកាលបរិច្ឆេទនៃការបិទផ្សាយ។ បញ្ជាក់ៈ ទីកន្លែង ត្រូវជ្រើសរើសទីកន្លែងណាមួយក្នុងតំបន់ធ្វើការវិនិច្ឆ័យ ដែលមានការងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការចូលរួមពិនិត្យទិន្នន័យ ដែលបានបិទផ្សាយជាសាធារណៈ ដូចជានៅទី វត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំ/សង្កាត់ សាលាស្រុក/ខណ្ឌ...។
- ក្នុងអំឡុងពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យគណៈកម្មការរដ្ឋបាលត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីនៅមូលដ្ឋានចាំបាច់ជាអាទិ៍ មេឃុំ/ចៅសង្កាត់ ឬតំណាងផ្លូវច្បាប់របស់ជននេះឱ្យប្រចាំការរង់ចាំទទួលបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយបញ្ហាតាមគោលការណ៍កំណត់។

សាមីអ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់របស់ជននេះ ដែលមិនទាន់យល់ស្របតាមការសំរេចបណ្តោះអាសន្នរបស់មន្ត្រីជំនាញ នៅពេលប្រតិបត្តិការកំណត់ព្រំដី ឬវិនិច្ឆ័យមានសិទ្ធិប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅគណៈកម្មការរដ្ឋបាលនៅពេលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ដើម្បីអោយគណៈកម្មការនេះ លើកយកមកដោះស្រាយឡើងវិញ។ ករណីមិនអាចដោះស្រាយបានគណៈកម្មការរដ្ឋបាលត្រូវបញ្ជូនសំណុំរឿងវិវាទនោះទៅគណៈកម្មការសុរិយោដីធ្វើការដោះស្រាយបន្ត។ បណ្តឹងនីមួយៗ ត្រូវបានកត់ត្រាដាច់ដោយឡែកពីគ្នា ហើយត្រូវមានបញ្ជាក់ ច្បាស់លាស់អំពីកម្មវត្ថុនៃបណ្តឹង ឈ្មោះ និង

ស្នាមមេដៃម្ចាស់បណ្តឹង ឈ្មោះ និងហត្ថលេខាមន្ត្រីទទួលកត់ត្រា និងមានការបញ្ជាក់ដឹងឮពីមេឃុំចៅសង្កាត់ ឬតំណាងច្បាប់របស់ជននោះ ។

*** នៅដំណាក់កាលទី ៤ :**

• ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យគណៈកម្មការរដ្ឋបាល ត្រូវធ្វើរបាយការណ៍ ស្តីពីលទ្ធផលនៃការវិនិច្ឆ័យតាមខ្លឹមសារខាងក្រោម :

**ក-លទ្ធផលដែលសំរេចបាន :**

- ចំនួនក្បាលដីសរុបដែលបានធ្វើការវិនិច្ឆ័យ
- ចំនួនក្បាលដែលមិនត្រូវបានចេញប័ណ្ណជូន ដោយការកាន់កាប់ដីរដ្ឋចាប់ពីក្រោយច្បាប់ភូមិបាលចូលជាធរមាន
- ចំនួនក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានវិវាទ
- ចំនួនក្បាលដីដែលមានវិវាទ
- ចំនួនក្បាលដីដែលមានវិវាទ ដែលគណៈកម្មការរដ្ឋបាល បានដោះស្រាយរួចតាមការព្រមព្រៀង
- ចំនួនក្បាលដីដែលមានវិវាទ ហើយបានបញ្ជូនទៅគណៈកម្មការសុរិយោដី
- ចំនួនក្បាលដីដែលពុំមានបណ្តឹងទៅតុលាការ

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវរៀបចំនូវគំរូរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ ។

**ខ- ធ្វើការវាយតំលៃ លើកសំណើផ្តល់សិទ្ធិលើដី ឬអចលនវត្ថុតាមប្រភេទកម្មសិទ្ធិភោគ :** សម្បទាន ឬរក្សាទុកជាដីរដ្ឋជូនកម្មសិទ្ធិករ ភោគី ឬអ្នកកាន់កាប់ដោយយោងទៅតាមច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត និងឯកសារ ឬភស្តុតាង ដែលប្រមូលបាន ។

- ប្រធានគណៈកម្មការរដ្ឋបាលត្រូវចុះហត្ថលេខាលើប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដីនិងរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ ។

*** នៅដំណាក់កាលទី ៥ :** ជាការងារជំនាញ ។ ការចេញប័ណ្ណគឺ ផ្អែកតាមការវាយតំលៃ និងសំណើផ្តល់សិទ្ធិរបស់គណៈកម្មការរដ្ឋបាល ។

**គោលការណ៍ចេញប័ណ្ណ:**

*១-ចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ* (ប័ណ្ណកម្មសិទ្ធិ) ចំពោះក្បាលដី ឬអចលនវត្ថុណាដែលបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃ ការប្រកាសអោយប្រើច្បាប់ភូមិបាល (មាត្រ ៣០ នៃច្បាប់ភូមិបាល ) ។

*២-ចេញប័ណ្ណកម្មសិទ្ធិកាន់កាប់អចលនៈវត្ថុ* (ប័ណ្ណភោគៈ) ចំពោះក្បាលដី ឬអចលនៈវត្ថុណាដែលបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ ហើយមានរយៈពេលតិចជាង ៥ឆ្នាំ មុនច្បាប់ភូមិបាលចូលជាធរមាន ។ ប័ណ្ណប្រភេទនេះ អាចប្តូរយកវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ នៅពេលដែលរយៈពេលនៃការកាន់កាប់ដី ឬអចលវត្ថុនោះបានគ្រប់ ៥ ឆ្នាំ ឬលើស ។

*៣-អាចចេញប័ណ្ណជូនបានចំពោះតែក្បាលដី ឬអចលនវត្ថុណាដែលគ្មានពាក់ព័ន្ធនឹងវិវាទ ។*

* តើបេសកម្មរបស់គណៈកម្មការរដ្ឋបាល ចប់នៅពេលណា?

ភារកិច្ចរបស់គណៈកម្មការរដ្ឋបាល កំណត់ក្នុងមាត្រ ៣ នៃអនុក្រឹត្យគឺ:

- បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី
- ទទួលរាល់បណ្តឹងតវ៉ាធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង
- ធ្វើសេចក្តីសន្និដ្ឋាន ផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ
- លើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ ។

---

*អត្ថបទដោយ បណ្តាញសកម្មភាពដីធ្លីដើម្បីអភិវឌ្ឍន៍ LAND*

## ការឈូសឆាយព្រៃធម្មជាតិ គឺជាទុក្ខកង្វល់របស់សហគមន៍

### ១-បញ្ហាព្រៃឈើ

គោលនយោបាយកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិតាមរយៈសម្បទានដីសេដ្ឋកិច្ច បានទាក់ទាញការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់ក្រុមហ៊ុនវិនិយោគទាំងក្នុងស្រុក និងបរទេស។ តំបន់ព្រៃឈើដ៏ធំល្វឹងល្វើយនៅក្នុងបណ្តាខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានឈូសឆាយ និងប្រែក្លាយជាទីវាលរហោស្ថាន ដើមឈើធម្មជាតិដ៏មានតម្លៃរាប់លានដើមកំពុងដួលរលំជាបន្តបន្ទាប់គួរសង្វេគ។ ជាមួយគ្នានេះដែរ តម្លៃដីធ្លីមានការកើនឡើងយ៉ាងគំហុកជាហេតុនាំឱ្យចលនាផ្លាស់ប្តូរទីលំនៅ និងមានការទិញលក់ដីធ្លីគ្រប់ទីកន្លែង ជាពិសេសតំបន់ព្រៃឈើបានក្លាយទៅជាមុខទំនិញយ៉ាងពេញនិយម។ ចលនានេះកំពុងគម្រាមកំហែងដល់ភាពសុខសាន្តនៃ



ការជួបសម្ភាសន៍រវាងក្រុមការងារដីធ្លីដើម្បីអភិវឌ្ឍន៍ LAND និងសហគមន៍មូលដ្ឋានដែលកំពុងព្រួយបារម្ភពីការបាត់បង់ធនធានធម្មជាតិ និងដីធ្លី

សហគមន៍មូលដ្ឋាននៅក្នុងតំបន់ ដែលមានជីវភាពរស់នៅដោយពឹងផ្អែកទៅលើធនធានព្រៃឈើ ដូចជាការដងជ័រទឹក រកជ័រចុង បោចវល្លិ៍ រកបន្លែ និងផ្លែឈើព្រៃ និងធ្វើចំការវិលជុំជាដើម។ មានប្រជាពលរដ្ឋជាច្រើនគ្រួសារនៅក្នុងតំបន់នេះ គឺជាអ្នកចំណាកស្រុកមកពីបណ្តាលខេត្តមួយចំនួនដូចជា: ខេត្តបាត់ដំបង កំពង់ចាម សៀមរាប តាកែវ កំពត បន្ទាយមានជ័យ កំពង់ធំ និងព្រះវិហារ។ ពួកគេមករស់នៅទីនោះ តាមរយៈបងប្អូនមិត្តភ័ក្រ្តក្នុងគោលបំណងច្រើនយ៉ាងដូចជា: ១) ធ្វើកសិកម្ម ព្រោះ គេយល់ឃើញថាតំបន់នេះមានដីទំនេរច្រើន ២) លក់កម្លាំង ពលកម្មឱ្យក្រុមហ៊ុន តាមរយៈការកាប់ឈើក្នុងតំបន់ព្រៃសហគមន៍ ៣) រានព្រៃដើម្បីយកដីលក់បន្ត។

ទទ្ទឹមនិងការកាប់រានព្រៃយកដី សកម្មភាពនាំឈើចេញក៏បាននឹងកំពុងដំណើរការផងដែរ។ ឈើសំណង់ និងឈើប្រណិតជាច្រើនត្រូវបានដឹកចេញទៅកាន់ប្រទេសថៃតាមច្រកអូរស្មាច់ និងចេញតាមច្រកជាំស្រងាម និងអន្លង់វែងទៅកាន់ខេត្តសៀមរាប និងបន្ទាយមានជ័យ។

តាមរយៈអ្នករកស៊ីកាប់ឈើ បានឱ្យដឹងថា តម្លៃឈើប្រណិតនៅលើទីផ្សារក្នុងតំបន់មានការកើនឡើងយ៉ាងខ្លាំង ជាហេតុនាំឱ្យឈើប្រភេទនេះកំពុងប្រឈមមុខ និងការគំរប្រភេទឈើ ប្រណិតមួយចំនួនដូចជា ក្រញូង បេង នាងនួន និងធ្នង់ ១ម៉ែត្រត្រីគុណ ទិញចូលតម្លៃ ៣០០-៦០០ដុល្លារ លក់ចេញតម្លៃ ៧០០-២០០០ដុល្លារ។

## ២_ការព្រួយបារម្ភរបស់សហគមន៍

បច្ចុប្បន្នភូមិចំនួន ១៣ នៃស្រុក ចុងកាល់ កូន ត្រៀល និងស្រុកសំរោងនៃខេត្តឧត្តរមានជ័យកំពុងប្រឈមមុខនឹងការបណ្តេញចេញដោយគ្មានដំណោះស្រាយ។ ខាងក្រោមនេះគឺជាទូរលេខនៃចំនួនប្រជាពលរដ្ឋ និងទំហំដីនៃភូមិដែលកំពុងជួបបញ្ហា:

១. ភូមិដូនកែនមានប្រជាពលរដ្ឋ ២៩២ គ្រួសារ និងទំហំដី១១១០ហិតា

| | | | | |
|---|---|---|---|---|
| ២. ភូមិឈូក | = | ១៦៥ គ្រួសារ | ទំហំដី | ៥៧០ហិតា |
| ៣. ភូមិអូរក្រវ៉ាន់ | = | ៣៨ គ្រួសារ | ទំហំដី | ១៤៧ហិតា |
| ៤. ភូមិគោកគ | = | ៧៤ គ្រួសារ | ទំហំដី | ៧២ហិតា |
| ៥. ភូមិពល់ | = | ៣០៤ គ្រួសារ | ទំហំដី | ១១៦១ហិតា |
| ៦. ភូមិឆ្អើប | = | ១៤៥ គ្រួសារ | ទំហំដី | ១២២៥.៥ហិតា |
| ៨. ភូមិកូនដំរី | = | ៥៣ គ្រួសារ | ទំហំដី | ១៥៣.១ហិតា |
| ៩. ភូមិគោកច្រេស | = | ៥៦គ្រួសារ | ទំហំដី | ៣០១ហិតា |
| ១០. ភូមិត្រពាំងវែង | = | ៩០ គ្រួសារ | ទំហំដី | ៣៦៩ហិតា |
| ១១. ភូមិទាមមាន់ | = | ៤៧ គ្រួសារ | ទំហំដី | ២៨៦ហិតា |
| ១២. ភូមិខ្ទុំ | = | ១៦៣ គ្រួសារ | ទំហំដី | ១៣៥៣ហិតា |
| ១៣. ភូមិបាក់នឹម | = | ២៤១ គ្រួសារ | ទំហំដី | ២៦,០៣៦ហិតា |



ដីព្រៃឈើដែលបានឈូសឆាយ

ដោយសារការព្រួយបារម្ភអំពីផលប៉ះពាល់ទៅលើជីវភាពរស់នៅរបស់ខ្លួនប្រជាពលរដ្ឋទាំង១៣ភូមិបាននាំគ្នាធ្វើពាក្យបណ្តឹងមកកាន់ការិយាល័យវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។

តាមការអះអាងរបស់ប្រជាពលរដ្ឋ និងអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់នៅក្នុងតំបន់បានឱ្យដឹងថា មានក្រុមហ៊ុនចំនួន៨ ដែលបាននឹងកំពុង



ការកាប់ឈើ និងដឹកជញ្ជូនឈើខុសច្បាប់

ធ្វើសកម្មភាព ៖

១.ក្រុមហ៊ុនវៀលគ្រីន៨,០០០ហិកតា,ដាំអំពៅ)

២.គ្រីសស្គាល់អាក្រូ៨,០០០ហិកតា,ដាំអំពៅ)

៣.មៀងលីហេង១,០០០ហិកតា ,ដាំល្ហុងប្រេង)

៤.ក្រុមហ៊ុន កែវ សម្បត្តិ ៣,០០០ហិកតា)

៥.សុវណ្ណឧត្តរ៩០០ហិកតា) ។

៦.ខេមបូឌា ខេន អេន ស៊ូហ្គើរ វែលលី ១២.២៥៦ ហិកតា)

៧.អង្គរ ស៊ូហ្គើរ ១០.៩៣០ ហិកតា)

៨.ទន្លេស៊ូហ្គើរខេន ១២.២៥៦ ហិកតា)

លោក **ឃុំ សុខុន** ជំទប់ទី១ ឃុំសំរោង បានអះអាងថា ការឈូសឆាយដីព្រៃបានធ្វើឱ្យប៉ះពាល់ដល់ដីប្រជាពលរដ្ឋយ៉ាងច្រើន។ ពួកគេបានប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជួយរកដំណោះស្រាយអំពីដីព្រៃមួយចំនួនដែលពួក គាត់ការពារទុកសម្រាប់ការបង្កើតសហគមន៍ព្រៃឈើ ក៏ប៉ុន្តែរហូតមកដល់ពេលនេះ ពុំទាន់ឃើញមានដំណោះស្រាយណាមួយនៅឡើយ។ លោក **មុត ឪុឌ** អភិបាលរងស្រុកសំរោង បានឱ្យដឹងថា ៖ ក្រុមហ៊ុនចំនួន ៣ កំពុងឈូសឆាយព្រៃស្រោងនៅក្នុងឃុំកូនក្រៀល ស្រុកសំរោង និង ឃុំពង្រ ស្រុកចុងកាល់។

ទាក់ទងនឹងបញ្ហានេះ លោក **យឹម ធិន** បានឱ្យដឹងថា ខេត្តឧត្តរមានជ័យមានផ្ទៃដី <u>*៦,០០០គីឡូម៉ែត្រក្រឡា*</u> ជាប្រភេទព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃរបោះ និងព្រៃរិចរិល។ លោកបានបន្ថែមទៀតថា សកម្មភាពកាប់ទន្រ្ទានព្រៃឈើដើម្បីយកដីលក់ តែងតែកើតមានឡើងជារៀងរាល់ ដោយសារការទិញលក់ដីធ្លីដោយមានការគាំទ្រពីអ្នកមានអំណាច។

*អត្ថបទដោយ លោក **ស៊ឹម តារា** មន្រ្តីស៊ើបអង្កេតនៃ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*



# ក្រុមហ៊ុនលីយ៉ុងផាត់មានតំរោងអភិវឌ្ឍន៍នៅឃុំត្រពាំងជោ ប្រជាពលរដ្ឋមានការបារម្ភសុំឱ្យក្រុមហ៊ុនគោរពតាមកិច្ចសន្យា

ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ៖ ដោយស៊ុនសារះមេឃ(មីសាចក្រហម)

ប្រជាពលរដ្ឋអញ្ជើញមកពីភូមិចំនួន៣ គឺភូមិចាន់ពីង ភូមិក្រាំងតៀង ភូមិផ្តោចចំនួន២៣៤នាក់ ជាតំណាងស្ថិតនៅក្នុងភូមិសាស្រ្ត ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បានជួបជុំគ្នាកាលពីថ្ងៃទី ១១ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង០៩.២០នាទីព្រឹក រហូតដល់ម៉ោង១២.០០នាទីថ្ងៃត្រង់ កន្លែងសាលា ឃុំត្រពាំងជោ ដើម្បីនាំគ្នាផ្តិតមេដៃគាំទ្រដល់ការអភិវឌ្ឍន៍របស់ក្រុមហ៊ុនលី យ៉ុងផាត់ ដែលមានអ្នក ស្រីវរៈសេនីយ៍ត្រី ឈាង គីមស៊ុន ធ្វើការនៅក្រសួងមហាផ្ទៃ នាយកដ្ឋានស្ថាបនា ជាតំណាងក្រុមហ៊ុន ។ ក្នុងឱកាសនោះ មានការអញ្ជើញចូលរួមពីសំណាក់ក្រុម

ឯកឧត្តម-អ្នកឧកញ៉ា លី យ៉ុងផាត់

ប្រជាពលរដ្ឋស្នើសុំឱ្យក្រុមហ៊ុនលីយ៉ុងផាត់គោរពពាក្យសន្យា

តទៅទំព័រទី ៣ ខ

រូបភាពកាសែតនេះ ដកស្រង់ចេញពីកាសែតវាចាខ្មែរ
ចុះផ្សាយឆ្នាំទី ២ លេខ ៣៣ ចេញផ្សាយសំរាប់ថ្ងៃសុក្រ ទី ២៤ ខែសីហា ឆ្នាំ ២០០៧ អំពីបញ្ហាដីធ្លីនៅក្នុងឃុំត្រពាំងជោ

# ស្ថានភាពទំនាស់ដីធ្លី និងព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងត្រីមាសទី១ នៃ ឆ្នាំ២០០៨

នាពេលបច្ចុប្បន្ននេះ បញ្ហាទំនាស់ដីធ្លីត្រូវបានគេទទួលស្គាល់ថាជាបញ្ហាដ៏ក្ដៅគគុកមួយដែលតែងតែ កើតមានឡើងគ្រប់ទីកន្លែងទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជា។ ស្ទើរតែគ្មានលោះមួយថ្ងៃណាសោះ ដែលព័ត៌មានទាំងនេះត្រូវបានលើកមកនិយាយតាមរយៈបណ្ដាញសារព័ត៌មានសំខាន់ៗប្រចាំថ្ងៃ។ ព័ត៌មាន ដែលពាក់ព័ន្ធទៅនឹងបញ្ហាដីធ្លីនេះដ៏ទៃទៀតក៏ត្រូវបានលើកមកផងដែរ ដូចជាការកាប់រានបំផ្លាញព្រៃឈើ ដើម្បីយកដី ការរត់ពន្ធផលដែលបានពីព្រៃឈើខុសច្បាប់ ដែលជាហេតុអាចបណ្ដាលអោយប្រជាពលរដ្ឋរងទុក្ខវេទនា និងជួនកាលមានរហូតដល់ត្រូវបណ្ដេញចេញពីលំនៅដ្ឋានដោយបង្ខំដោយសារបញ្ហាទាំងនេះ។ កន្លងមក មានប្រជាជនរាប់រយពាន់ម៉ឺននាក់ហើយដែលបាននឹងកំពុងទទួលរងផលប៉ះពាល់ពីបញ្ហាទាំងអស់នេះ។

បញ្ហាទាំងនេះ ត្រូវបានមើលឃើញ និងទទួលស្គាល់ទាំងបណ្ដាអង្គការសង្គមស៊ីវិលភ្នាក់ងារជំនួយអន្តរជាតិ និងរាជរដ្ឋាភិបាលកម្ពុជាថាជាបញ្ហាក្ដៅ និងតម្រូវអោយមានវិធានការជាបន្ទាន់នៅក្នុងពេលបច្ចុប្បន្ននេះ។ គំរោងដីធ្លី និងជីវភាពរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា មានតួនាទីយ៉ាង សំខាន់មួយក្នុងការបញ្ជូនព័ត៌មានដែលទាក់ទងទៅនឹងបញ្ហាដី និងព្រៃឈើពីថ្នាក់មូលដ្ឋានទៅដល់ថ្នាក់គោលនយោបាយជាតិ និងបណ្ដាសង្គមស៊ីវិលអន្តរជាតិដ៏ទៃទៀត។ ដើម្បីឆ្លើយតបទៅនឹងតំរូវការព័ត៌មានទាន់ហេតុការណ៍ និងគ្រប់ជ្រុងជ្រោយបាននោះ មជ្ឈមណ្ឌល ព័ត៌មានដីធ្លីត្រូវបានបង្កើតឡើង។ ការចងក្រង និងប្រមូលផ្ដុំសារព័ត៌មាន តាមរយៈកាសែតសំខាន់ៗនេះគឺជាមធ្យោបាយមួយដែលអាចបង្ហាញពីនិន្នាការ និងកំរិតនៃបញ្ហាជារួមដែលទាក់ទងនឹងបញ្ហាដីធ្លីនៅក្នុងកំឡុងរយៈពេលបីខែដំបូង។ ទិន្នន័យដែលបង្ហាញនៅក្នុងអត្ថបទនេះ គឺបានមកពីការប្រមូលព័ត៌មានសង្ខេបរយៈពេលបីខែដំបូងនៃដើមឆ្នាំ២០០៨ តាមសារព័ត៌ មាននានា ដូចជារស្មីកម្ពុជា កោះសន្តិភាព ឌឺខេមបូឌាដេលី និងគេហទំព័រនៃវិទ្យុអាស៊ីសេរី។

តាមការសង្កេតនៅក្នុងរយៈពេលបីខែដើមឆ្នាំ២០០៨ នេះ មជ្ឈមណ្ឌលព័ត៌មានដីធ្លីនៃវេទិការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា បានមើលឃើញថា មានបញ្ហាធំពីរកំពុងកើតមានឡើងយ៉ាងខ្លាំងក្លានៅក្នុងប្រទេសកម្ពុជាក្នុងនោះរួមមាន ៖ ១. បញ្ហាជំលោះដីធ្លី ដោយរួមមានទាំងការបណ្ដេញចេញ ដោយបង្ខំ និងមិនបង្ខំ និង ២. ការកាប់បំផ្លាញព្រៃសហគមន៍ និងការរត់ពន្ធឈើខុសច្បាប់។

## ១. បញ្ហាវិវាទដីធ្លី

មានមិនតិចជាង ៥០០ អត្ថបទទេក្នុងរយៈពេលបីខែដើមឆ្នាំ២០០៨ នេះ ដែលបានផ្សព្វផ្សាយ កន្លងមកពាក់ព័ន្ធទៅនឹងបញ្ហាដីធ្លីក្នុងនោះមានជាង ១៥០ ករណីទំនាស់ដីធ្លីៗទាំងតូចទាំងធំ ដែលបានកើតឡើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការវិភាគជារួម ទំនាស់ដីធ្លីជាទូទៅគឺក្រុងព្រះសីហនុ មានអត្រាច្រើនជាងគេ ១៥ភាគរយ (%) បើប្រៀបធៀបទៅបណ្ដាខេត្តដ៏ទៃនៅក្នុងរយៈពេលដូចគ្នានេះ។ តំបន់ដែលមានទំនាស់ធំបន្ទាប់គឺនៅរាជធានីភ្នំពេញដែលមានតួលេខស្មើនឹង ១១ % នៃទំនាស់ទូទាំងប្រទេសសរុប។ កំរិត និងទំហំនៃវិវាទដីធ្លីនេះក៏កើតមានជាច្រើនដែរនៅតាមបណ្ដាខេត្តផ្សេងៗ ដូចជា ខេត្តបន្ទាយមានជ័យ ៧% កំពត ៧% រតនគិរី ៧% កណ្ដាល ៧% សៀមរាប ៦% និងឧត្តរមានជ័យ ៦% ជាដើម។

គួរអោយកត់សំគាល់ក្នុងចំណោមករណីវិវាទដីធ្លីទាំងអស់មាន ៨ភាគរយ ប៉ះពាល់ទៅនឹងការរស់នៅ និងប្រកបរបររបស់ជនជាតិដើមភាគតិចជាពិសេសនៅខេត្តរតនគិរី។ ប្រមាណ ២០% នៃទំនាស់ជារួម គឺការបណ្ដេញចេញដោយបង្ខំ ដូចជាការដុតបំផ្លាញផ្ទះសម្បែង ការចាប់ឃុំខ្លួនប្រជាពលរដ្ឋ និងការបាញ់ប្រហារជាដើម។

ជាទូទៅ ការដោះស្រាយទំនាស់ដីធ្លីទាំងឡាយនៅមានលក្ខណៈយឺតយ៉ាវច្រើន ។ ជាក់ស្ដែងមាន ប្រមាណ ៨០% នៃទំនាស់គឺនៅមិនទាន់មានការដោះស្រាយ និងកំពុងប្ដឹងតវ៉ាជំទាស់ទៅនឹងសេចក្ដីសំរេចរបស់អជ្ញាធរ ឬតុលាការ។ មានមូលហេតុជាច្រើនដែលធ្វើអោយការដោះស្រាយមានសភាពយឺតយ៉ាវ។ ទំនាស់ដែលអូសបន្លាយយូរអង្វែងនោះ ភាគច្រើនគឺទំនាស់ធំៗដែលពាក់ព័ន្ធរវាងប្រជាជនក្រីក្រច្រើនគ្រួសារជាមួយអ្នកមានប្រាក់ ឬមន្ត្រីមានអំណាច។ ជិត ៤០ ភាគរយនៃករណីវិវាទដីធ្លី គឺពាក់ព័ន្ធជាមួយនឹងប្រជាពលរដ្ឋច្រើនជាង ៥០គ្រួសារ និងលើដីដែលមាន

ទំហំធំលើសពី ៥០ ហិកតា។ ទោះជាយ៉ាងណាក៏ដោយ ស្ទើរតែពាក់កណ្តាលនៃករណីដែលបានផ្សព្វផ្សាយ មិនមានបង្ហាញតួរលេខច្បាស់លាស់អំពីចំនួនប្រជាពលរដ្ឋរងគ្រោះ និងទំហំដីវិវាទនោះឡើយ។

ការកើនឡើងនៃតំលៃដីធ្លីនាពេលបច្ចុប្បន្ន ធ្វើអោយការទិញលក់ដីមានការកើនឡើងយ៉ាងគគ្រឹកគគ្រេង គឺជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនដែលជាហេតុនាំឱ្យទំនាស់ដីធ្លីកើនឡើង។ បច្ចុប្បន្ននេះ ប្រជាពលរដ្ឋមួយចំនួនធំកំពុងទទួលរងការរំលោភ និងបោកបញ្ឆោតយកដីពីសំណាក់អ្នកមានប្រាក់ និងអ្នកមានអំណាច ដូចជាក្រុមហ៊ុនឯកជន មន្ត្រីយោធា ដែលមានឥទ្ធិពលជាដើម។ ជាលទ្ធផលប្រជាកសិករគឺ ជាអ្នកបាត់បង់ដីស្រែចំការ ដែលជាអាយុជីវិតរបស់ពួកគាត់។

យើងសង្កេតឃើញថានៅចុងត្រីមាសទីមួយនៃឆ្នាំ២០០៨ នេះ ករណីទំនាស់ដីធ្លីមួយចំនួនត្រូវបានដោះស្រាយតាមរយៈការចុះអន្តរាគមន៍ពីសំណាក់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដោយសារតែភាពអសកម្មរបស់ស្ថាប័នទទួលបន្ទុកការដោះស្រាយវិវាទដីធ្លី។ ករណីនេះធ្វើឱ្យសាធារណៈមតិបានលើកឡើងថា ហេតុអ្វីចាំបាច់ទាល់តែមានការបញ្ជាដោយផ្ទាល់ពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន ទើបការដោះស្រាយអាចបញ្ចប់ទៅបានដោយជោគជ័យ ឬក៏មន្ត្រីមូលដ្ឋាន និងស្ថាប័នជំនាញទាំងនោះពិតជាខ្វះសមត្ថភាពក្នុងការដោះស្រាយមែនឬ?

## ២. បញ្ហាព្រៃឈើ និងការរត់ពន្ធខុសច្បាប់

ក្នុងរយៈពេលបីខែដើមឆ្នាំ២០០៨ នេះ បទល្មើសព្រៃឈើមានចំនួនដល់ទៅ ៤៣ ករណី។ ក្នុងចំណោមខេត្តទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ខេត្តស្ទឹងត្រែងឈរលំដាប់ថ្នាក់ទីមួយ ខេត្តពោធិសាត់ ឈរលំដាប់ទីពីរ និងខេត្តក្រចេះ និងឧត្តរមានជ័យ ឈរលំដាប់ទីបី ក្នុងការកាប់ឈើ និងរត់ពន្ធឈើចេញទៅខេត្តផ្សេងៗ និងទៅប្រទេសវៀតណាម។ ដោយឡែកតាមរយៈព័ត៌មានដែលយើងទទួលបានពីប្រភពនានា យើងសង្កេតឃើញថា ខេត្តសៀមរាប និងរាជធានីភ្នំពេញ គឺជាខេត្តដែលមានតំរូវការឈើប្រណិតខ្ពស់ជាងគេ។ ក្រៅពីការនាំឈើទៅកាន់ខេត្តសៀមរាប និងរាជធានីភ្នំពេញការរត់ពន្ធឈើលំដាប់ទីពីរ គឺការនាំឈើចេញទៅប្រទេសវៀតណាម និងលើសពីនេះនៅមានករណីនាំឈើចេញដោយខុសច្បាប់ជាច្រើនទៀតដែលយើងមិនបានដឹងពីប្រភព និងទីតាំងចុងក្រោយ។ ឈើដែលមានតំរូវការខ្លាំងនោះ គឺសុទ្ធតែជាប្រភេទឈើប្រណិតដែលកំរដែលមានដូចជាឈើក្រញូង ឈើធ្នង់ ឈើគគីរ ឈើបេង និង នាងនួន ជាដើម។ បើតាមអត្ថបទរាយការណ៍ពីករណីរត់ពន្ធឈើខុសច្បាប់នៅក្នុងសារព័ត៌មានក្នុងរយៈពេលបីខែនេះ ឈើក្រញូងឈរនៅលំដាប់ទីមួយ ដែលមានតំរូវការខ្ពស់ និងមានការរត់ពន្ធខុសច្បាប់ជាច្រើនករណី។

ទោះបីជាយ៉ាងណាក៏ដោយតាមការអង្កេតជាទូទៅបង្ហាញអោយឃើញថា រាជរដ្ឋាភិបាលក៏មានការ ខិតខំប្រឹងប្រែង និងចាត់វិធានការច្រើនផងដែរ នៅក្នុងការទប់ស្កាត់ការរត់ពន្ធឈើប្រណិតខុសច្បាប់ទាំងនោះ ដូចជាការសហការរួមគ្នារវាងអាជ្ញាធរមូលដ្ឋាន មន្ត្រីរដ្ឋបាលព្រៃឈើ និងកងកម្លាំងប្រដាប់អាវុធដែល ប្រចាំការនៅតាមតំបន់។ ជាក់ស្តែងវិធានការដែលបានដាក់ចេញមានដូចជា ការចុះបង្ក្រាបរោងម៉ាស៊ីនអាឈើ ការហាមឃាត់ការកាប់រានព្រៃខុសច្បាប់ នៅក្នុងខេត្តសៀមរាប ពោធិសាត់ ស្ទឹងត្រែង និងកំពង់ចាម។

ទោះបីជាមានការរឹតបន្តឹងយ៉ាងណាក៏ដោយ ក៏សកម្មភាពកាប់បំផ្លាញព្រៃឈើ និងការរត់ពន្ធឈើ ខុសច្បាប់នៅតែកើតមានជារៀងរាល់ថ្ងៃតាមរយៈឈ្មួញ និងមន្ត្រីដែលមានលុយ និងអំណាច។

*អត្ថបទដោយៈ មជ្ឈមណ្ឌលព័ត៌មានដីធ្លី នៃកម្មវិធីដីធ្លី និងជីវភាព*

*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

*ប្រភពទិន្នន័យៈ សារព័ត៌មាន កោះសន្តិភាព រស្មីកម្ពុជា ឌឺខេមបូឌាដេលី និងវិទ្យុអាស៊ីសេរី*

# និន្នាការរួមនៃការវិភាគករណីវិវាទដីធ្លីក្នុងខេត្តបីនៃព្រះរាជាណាចក្រកម្ពុជា ការអនុវត្តក្នុងតំបន់ចុះបញ្ជី

## ១. សេចក្តីផ្តើម

មណ្ឌលព័ត៌មានដីធ្លី (LIC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៧ នៅក្នុងកម្មវិធីដីធ្លី និងជីវភាពនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ មណ្ឌលព័ត៌មានដីធ្លី នេះបង្កើតឡើងដើម្បីធ្វើការប្រមូល និងចងក្រងព័ត៌មានស្តីពីវិវាទដីធ្លីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ នៅចុងឆ្នាំ២០០៧ មណ្ឌលព័ត៌មានដីធ្លីបានធ្វើការសាកល្បងវិភាគទៅលើរូបភាពជារួមលើបញ្ហាវិវាទដីធ្លីនៅក្នុងប្រទេសកម្ពុជា។ ប្រភពព័ត៌មានចំបងសំរាប់យកមកធ្វើការសិក្សានេះគឺទទួលបានពី អង្គការអុកស្វាមអង់គ្លេស (Oxfam, Great Britain (GB)) ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៤ ដែលបានធ្វើការប្រមូលតាមរយៈបណ្តាញនៃអង្គការជាដៃគូរបស់ខ្លួន។

ការសិក្សាសាកល្បងនេះ គឺធ្វើឡើងដោយការផ្ទៀងផ្ទាត់ព័ត៌មាន ដែលបានកត់ត្រាទុកនៅក្នុងប្រព័ន្ធទិន្នន័យរបស់អង្គការអុកស្វាមអង់គ្លេស ជាមួយនឹងការស៊ើបអង្កេតដោយផ្ទាល់ដល់ទីកន្លែងបន្ថែម ដើម្បីតាមដាន និងធ្វើបច្ចុប្បន្នភាពលើករណីវិវាទដីធ្លីទាំងនោះ។ ការសិក្សានេះក៏សំដៅប្រមូលផងដែរនូវករណីវិវាទដីធ្លីថ្មីៗ ដែលបានកើតឡើងតាំងពីឆ្នាំ២០០៥ នៅក្នុងបណ្តាខេត្តសាកល្បងទាំងនេះ។ ខេត្តចំនួនបី ដែលត្រូវបានជ្រើសរើសសំរាប់ធ្វើការស៊ើបអង្កេតនោះគឺ ខេត្តបាត់ដំបង កំពង់ធំ និងស្ទឹងត្រែង ដើម្បីជាគំរូមួយសម្រាប់ការវាយតម្លៃឱ្យបានកាន់តែលម្អិត។ ខេត្តទាំងបីនេះ ត្រូវបានជ្រើសរើសជាខេត្តសាក ល្បងសំរាប់ធ្វើការវាយតម្លៃករណីវិវាទដីធ្លី ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យ ៤ យ៉ាងខុសប្លែកពីគ្នាគឺ ស្ថានភាពភូមិសាស្ត្រ ចំនួនប្រជាជន ការប្រើប្រាស់ដី និងបណ្តាញអង្គការប្រមូលព័ត៌មាន។

## ២. ស្ថានភាពវិវាទដីធ្លី

ការវិភាគជារួមទៅលើករណីវិវាទដីធ្លីនេះគឺផ្តោតទៅលើទិន្នន័យ ដែលប្រមូលបានពីខេត្តចំនួនពីរប៉ុណ្ណោះ រួមមានខេត្តបាត់ដំបង ចំនួន ១០៤ ករណី និងខេត្តកំពង់ធំ ៤១ ករណី ។ ប៉ុន្តែ ការវិភាគនេះ មិនបាន រាប់បញ្ចូល ករណីវិវាទដីធ្លីចំនួន ៤ នៅក្នុងខេត្តស្ទឹងត្រែងនោះទេ ដោយ




រូបទី ១: មុខរបរ/ការពាក់ព័ន្ធរបស់ចុងចោទ គិតតាមសមាមាត្រចំនួនករណីវិវាទដីធ្លី។

[១] ពាក្យ **អ្នកប្តឹង** និង**ចុងចោទ**នឹងត្រូវបានប្រើនៅក្នុងរបាយការណ៍ទាំងមូល។ បច្ចេកស័ព្ទជន**រងគ្រោះ** និង**ជនល្មើស** ត្រូវបានប្រើកាលពីពេលមុននៅក្នុងមូលដ្ឋានទិន្នន័យដើម ប៉ុន្តែ ពាក្យនេះគឺជាពាក្យលំអៀងមួយអាស្រ័យលើទស្សនៈរបស់អ្នកប្រមូលទិន្នន័យវិវាទដីធ្លី។

សារករណីមានចំនួនតិចពេក។ លទ្ធផលនៃការវិភាគលើករណីវិវាទដីធ្លីចំនួន ១៤៥ បានបង្ហាញអោយឃើញថា ករណីវិវាទដីធ្លី ដែលអ្នករងគ្រោះភាគច្រើនជាសហគមន៍ជនបទនោះមាន៩០%។ ប្រមាណ៦០% នៃអ្នកប្តឹង[២] ដើម្បីការពារកម្មសិទ្ធិស្របច្បាប់របស់ខ្លួន មានឯកសារផ្លូវការតិចតួច ឬស្ទើតែគ្មាន។

ជាទូទៅ យើងសង្កេតឃើញថា នៅក្នុងខេត្តបាត់ដំបង ករណីវិវាទដីធ្លី ដែលចុងបណ្តឹងជាមន្ត្រីរដ្ឋាភិបាល ឬជាកងកម្លាំងប្រដាប់អាវុធជាពិសេសទាហាន មានប្រមាណ ៣០ ទៅ ៥០%។ ក្រៅពីនេះ ប្រមាណ ១០% នៃករណីវិវាទដីធ្លី ដែលចុងបណ្តឹងជាក្រុមហ៊ុនឯកជន។

យើងសង្កេតឃើញថា នៅក្នុងខេត្តបាត់ដំបង ករណីវិវាទដីធ្លី ប្រមាណ ៣០% មានការគម្រាមកំហែង និងការបណ្តេញចេញដោយប្រើហិង្សាដែលជាសមាមាត្រមួយដ៏គួរឱ្យបារម្ភ ប៉ុន្តែទោះជាយ៉ាងណាក៏ ដោយអ្នក ប្តឹងភាគច្រើនត្រូវបានអនុញ្ញាតឱ្យស្ថិតនៅលើដីវិវាទនោះដដែល។




រូបទី ២: វិធីយកដីរបស់ចុងចោទ តាមចំនួនករណី។

យន្តការដោះស្រាយទំនាស់ដីធ្លីជាផ្លូវការសំរាប់ករណីទាំងនេះ ហាក់បីដូចជាពុំសូវទទួលបានជោគជ័យឡើយ ព្រោះប្រមាណ ៥៥% នៃករណីវិវាទនៅតែបន្តអូសបន្លាយអស់រយៈពេលជាច្រើនឆ្នាំ។ គួរអោយកត់សំគាល់ផងដែរថា តាមរយៈយន្តការនៃការដោះស្រាយទំនាស់ដីធ្លីប្រមាណ ៦០% នៃករណីវិវាទដែលត្រូវបាន ដោះស្រាយ គឺយ៉ាងហោចណាស់ដីមួយចំណែក ត្រូវបានទៅខាងអ្នកប្តឹង។

រូបភាពខាងក្រោមនេះបង្ហាញពីស្ថានភាពនៃករណីវិវាទដីធ្លីជាទូទៅនៅក្នុងខេត្តកំពង់ធំ និងបាត់ដំបង និងបង្ហាញផងដែរអំពីទីតាំងដែលមានទំនាស់ ដើម្បីងាយស្រួលក្នុងការសិក្សានាពេលអនាគត។

## ៣. សេចក្តីសន្និដ្ឋាន

តាមរយៈការវិភាគទិន្នន័យនៃករណីវិវាទដីធ្លីនៅក្នុងខេត្តសាកល្បងចំនួន ៣ នេះ បានបង្ហាញអោយឃើញថា វិវាទដីធ្លីភាគច្រើន កើតមានលើប្រភេទដីសំរាប់ធ្វើកសិកម្មនៅទីជនបទ។ ជាងពាក់កណ្តាលនៃករណីវិវាទដីធ្លីសរុប ភាគីដើមបណ្តឹងមិនមានលិខិតស្នាមជាផ្លូវការសំរាប់សំគាល់កម្មសិទ្ធិស្របច្បាប់របស់ខ្លួនឡើយ។ ករណីវិវាទដីធ្លីរវាងប្រជាជនជាមួយអាជ្ញាធរមូលដ្ឋាន ឬទាហានមូលដ្ឋាន មានចំនួនជិតមួយភាគបី។ វិវាទដីធ្លីមួយចំនួនបានឈានទៅដល់ការប្រើអំពើហិង្សា ឬការបណ្តេញចេញដោយបង្ខំ។ យើងឃើញថា ការដោះស្រាយ ទំនាស់ដីធ្លីនៅមានភាពយឺតយ៉ាវនៅឡើយ ដោយទំនាស់ភាគច្រើនត្រូវបានអូសបន្លាយជាច្រើនឆ្នាំទើបដោះស្រាយរួច។

[២] ភាគីទាំងសងខាងអាចមានសិទ្ធិស្របច្បាប់លើដី ហេតុនេះមានតែប្រព័ន្ធតុលាការទេដែលអាចធ្វើសេចក្តីសម្រេចបាន។ ហេតុនេះពាក្យថា ជនរងគ្រោះនិងជនល្មើស ត្រូវបានជំនួស ដោយពាក្យ អ្នកប្តឹងនិងចុងចោទ វិញ។

រូបទី ៣៖ ដ្យាក្រាមនៃករណីវិវាទដីធ្លីដែលបានកត់ត្រានៅក្នុងខេត្តបាត់ដំបង និងកំពង់ធំ តាមចំនួនវិវាទក្នុងដែនរដ្ឋបាលនៃឃុំនីមួយៗ (កំណត់សម្គាល់៖ ដោយសារនេះជាទិន្នន័យឆ្នាំ១៩៩៨ ដែលឃុំមួយចំនួននៃខេត្ត បាត់ដំបង មិនទាន់បានដាក់បញ្ចូលទៅក្នុងការកំណត់ព្រំប្រទល់រដ្ឋបាលឃុំ របស់នាយកដ្ឋានភូមិសាស្ត្រ។ ហេតុនេះ ចំនួនវិវាទខ្លះប្រហែលជាមិនត្រូវបានរាប់បញ្ចូលទេ)។

**Kampong Thom Dispute Commune**




**Battambang Disputed Communes**




**ចំណាំ៖** ទិន្នន័យស្តីអំពីវិវាទដីធ្លីនេះ គឺឆ្លុះបញ្ចាំងតែនៅក្នុងទីកន្លែងដែលបានសិក្សាតែប៉ុណ្ណោះ ហើយភាគរយដែលបង្ហាញនៅក្នុងការវិភាគនេះ អាចមានភាពលំអៀងខ្លះដោយសារទិន្នន័យមួយចំនួនពុំមានព័ត៌មាន។ ដូច្នេះរាល់ការប្រើប្រាស់បន្តសំរាប់ជាឯកសារយោង គួរគប្បីធ្វើការវិភាគ ដោយប្រុងប្រយ័ត្ន។

*អត្ថបទដោយ៖ មជ្ឈមណ្ឌលព័ត៌មានដីធ្លី នៃកម្មវិធីដីធ្លី និងជីវភាព*

*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

# គំនូសតារាងបង្ហាញអំពីដំណាក់កាលចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធ

## ក. ដំណាក់កាលនៃការចុះបញ្ជីដីធ្លី

**១.ដំណាក់កាលត្រៀមរៀបចំ:**

- កិច្ចប្រជុំផ្សព្វផ្សាយប្រកាសកំណត់តំបន់វិនិច្ឆ័យ
- ការប្រមូលព័ត៌មាននៅភូមិ
- ក្រោយពីតំបន់បានប្រកាសជាតំបន់វិនិច្ឆ័យអ្នកកាន់កាប់ដីព្រមទាំងអ្នកពាក់ព័ន្ធត្រូវចូលរួម
- ចំនួនគ្រួសារក្នុងភូមិចំនួនប្រមាណក្បាលដី ចំនួនដីទំនាស់ដីរដ្ឋ និងដីឯកជនប្រហាក់ប្រហែលត្រូវបានផ្តល់ដោយមេភូមិ

**២.ដំណាក់កាលប្រតិបត្តិការបច្ចេកទេស:**

**-ការកំណត់ព្រំ និងវាស់វែង:**

អ្នកកាន់កាប់ដី និងអ្នកពាក់ព័ន្ធត្រូវចូលរួមក្នុងសកម្មភាពកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យសិទ្ធិចំពោះក្បាលដី

**-ការព្រមព្រៀងរវាងអ្នកជាប់ព្រំ:**

លទ្ធផលនៃការព្រមព្រៀងគឺការផ្តិតមេដៃ។ ការផ្តិតមេដៃពុំមែនស្ថាពរទេ អ្នកអាចមានសិទ្ធិតវ៉ាក្នុងពេលបិទផ្សាយជាសាធារណៈរយៈពេល ៣០ ថ្ងៃក្រោយទៀត

**៣.ដំណាក់កាលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ:**

ម្ចាស់ដី/អ្នកកាន់កាប់ដី ចាំបាច់ត្រូវមកចូលរួមពិនិត្យមើលឯកសារនៃការវិនិច្ឆ័យ (ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី) ដើម្បីពិនិត្យផ្ទៀងផ្ទាត់លេខក្បាលដី ទំហំដី ឈ្មោះ និងប្រភេទទ្រព្យ។ ក្នុងករណីពិនិត្យឃើញថាមានកំហុសឆ្គងម្ចាស់ដី/អ្នកកាន់កាប់ដីត្រូវប្តឹងជំទាស់តវ៉ា ឬអាចសុំធ្វើការកែប្រែចូលមកគណៈកម្មាការរដ្ឋបាលនៅកន្លែងបិទផ្សាយ។ ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យមានរយៈពេល ៣០ថ្ងៃ

**៤.ដំណាក់កាលសំរេច :**

ក្រោយពេលការបិទផ្សាយជាសាធារណៈត្រូវបានបញ្ចប់ គណៈកម្មាការរដ្ឋបាលធ្វើរបាយការណ៍ជូនអភិបាលខេត្ត/ក្រុង ធ្វើការសំរេចលើឯកសារនៃការវិនិច្ឆ័យ

**៥.ដំណាក់កាលចុះបញ្ជី ចេញប័ណ្ណ និងចែកប័ណ្ណ :**

យោងឯកសារនៃការសំរេច ហើយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត/ក្រុង ត្រូវធ្វើការចុះបញ្ជី ចេញប័ណ្ណ និងចែកប័ណ្ណជូនប្រជាពលរដ្ឋម្ចាស់ដី

- ការចូលរួមមើលប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី
- យើងត្រូវចូលរួមពិនិត្យឱ្យទាន់ពេលវេលា ព្រោះពេលបិទផ្សាយមានតែ ៣០ ថ្ងៃទេ
- ការប្រគល់វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ។
- សុវត្ថិភាពស្ថាពរ និងភាពត្រឹមត្រូវតាមផ្លូវច្បាប់ត្រូវបានប្រគល់ជូនម្ចាស់ដីដែលពុំមានទំនាស់

## ខ. តំលៃសេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាពជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយតំរូវឱ្យម្ចាស់ដី/ឬអ្នកកាន់កាប់ដីបង់សេវានៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធតែម្តងគត់នៅពេលមកទទួលយកប័ណ្ណដូចតទៅ:

១.ដីកសិកម្មជនបទ ១រៀល/ម២ (១០០ រៀលសំរាប់ដីតូចជាង១០០ម២)
២.ដីលំនៅដ្ឋានជនបទ ១០រៀល/ម២
៣.ដីទីប្រជុំជនស្រុក ឬដីជាយទីប្រជុំជនខេត្ត ២០រៀល/ម២
៤.ដីទីប្រជុំជនខេត្ត ឬដីជាយទីប្រជុំជនក្រុងភ្នំពេញ ៥០រៀល/ម២
៥.ដីទីប្រជុំជនក្រុងភ្នំពេញ១០០ រៀល/ម២

## គ. ផលប្រយោជន៍នៃប័ណ្ណកម្មសិទ្ធិ

- ធានានូវសិទ្ធិរបស់អ្នកក្នុងការធ្វើជាម្ចាស់ ឬកាន់កាប់ដីធ្លី
- អាចយកទៅប្រើប្រាស់ជារបស់សំរាប់ធានាការខ្ចីប្រាក់បាន(ឧ.បញ្ចាំ)
- ជាឯកសារសំអាងនៅពេលមានជំលោះដីធ្លី
- ធ្វើឱ្យកាន់តែប្រសើរចំពោះការផ្ទេរអចលនវត្ថុ
- អាចបង្កើនតំលៃដីកាន់តែបានថ្លៃ ព្រោះទីផ្សារដីប្រកបដោយទំនុកចិត្ត

## ឃ. ការផ្លាស់ប្តូរ និងផ្ទេរសិទ្ធិនាពេលខាងមុខ

ដើម្បីធានាបាននូវសិទ្ធិស្របច្បាប់រាល់ការផ្លាស់ប្តូរ និងផ្ទេរសិទ្ធិត្រូវធ្វើការចុះបញ្ជីបន្តនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក/ខណ្ឌ។

- ភាពរីកចំរើន
- សុវត្ថិភាព និងស្ថេរភាព
- ការផ្ទេរកម្មសិទ្ធិ
- តើត្រូវផ្តល់ព័ត៌មានជូនអ្នកណា?

សំគាល់: ▬ លើកទឹកចិត្តអោយមានការចូលរួមពីម្ចាស់ដី

## វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

ការិយាល័យ : ផ្ទះលេខ ៩-១១, ផ្លូវ ៤៧៦ ទួលទំពូង ១ ភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ២១៤ ៤២៩

ទូរសារលេខ: ០២៣ ៩៩៤ ០៦៣

E-mail: ngoforum@ngoforum.org.kh

Website: www.ngoforum.org.kh




រូបភាពសាកសួរប្រជាពលរដ្ឋពីផលប៉ះពាល់នូវការឈូសឆាយដីសហគមន៍